ព្រះរាជាណាចក្រកម្ពុជា



ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

-----------

សំណុំរឿងព្រហ្មទណ្ឌ
លេខ : ១៨
ចុះថ្ងៃទី ៣០ ខែមិនា ឆ្នាំ១៩៩៩

សាលដីកា
លេខ : ២៧
ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០០០

ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០០០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១ _ ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ _ លោក ឈឹម ស៊ីផល ចៅក្រម

៣ _ លោក សោម សិរីវឌ្ឍ ចៅក្រមរបាយការណ៍

៤ _ លោក ទៀវ មួន ចៅក្រម

៥ _ លោក ស៊ិន នឹម ចៅក្រម

ក្រឡាបញ្ជី

លោក សុខ ប៊ុនលង

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ិនទៀង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៩៩ របស់ លោក ទៀង ស៊ីថា និង អ្នកស្រី ឱ្យ សម្បត្តិ ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៤៣៩ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល និង សំណុំរឿងព្រហ្មទណ្ឌលេខ ១៨ ចុះថ្ងៃទី ៣០ ខែ មិនា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

_ ពីបទ : ក្លែងបន្លំស្លាកទេដី ប្រព្រឹត្តនៅភូមិពាលតែញក ២ ឃុំផ្អះថ្ងៃព ស្រុក-សំពៅមាស ខេត្តពោធិ៍សាត់ កាលពីថ្ងៃទីខែ សីហា ឆ្នាំ ១៩៩៥ បទល្មើសដែលមានចែង-បញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា ៤៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះ នូ សម្បត្តិ "ម្ចាស់បណ្ដឹងសាទុក្ខ" ភេទស្រី អាយុ៦៥ឆ្នាំ ជាតិខ្មែរ - មុខរបរ មិនពិតប្រាកដ កើតនៅស្រុកបាភ្នំ ខេត្តព្រៃវែង សព្វថ្ងៃនៅ ភូមិក្បាលហុង ឃុំខ្វាល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ប្ដីឈ្មោះ លូ ហៀង "ស្លាប់" មានកូន ០៦នាក់ ។

- មេធាវី គ្មាន

- ជនជាប់ចោទឈ្មោះ ហៀង ស៊ីថា "ម្ចាស់បណ្ដឹងសាទុក្ខ" ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរ នគរបាលព្រហ្មទណ្ឌខេត្ត ទីលំនៅសព្វថ្ងៃ ភូមិពាលញែក ១ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ លូ ហៀង "ស្លាប់" ម្ដាយឈ្មោះ នូ សម្បត្តិ "រស់" ប្រពន្ធឈ្មោះ ខែម ចាន់ រស្មី មានកូន ០១នាក់ ។

- មេធាវី ឈ្មោះ ពុធ ធារី

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ស៊ុយ ហៀង "ចុងបណ្ដឹងសាទុក្ខ" ភេទស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិពាលញែក ២ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ឪពុកឈ្មោះខ្វាច់ ហាន់ "ស្លាប់" ម្ដាយឈ្មោះ គិត ឆេង "ស្លាប់" ប្ដីឈ្មោះឡាយ ឈួន មានកូន៣នាក់ ។

- មេធាវី គ្មាន

- តាមបណ្ដឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៩៩ របស់លោកហៀង ស៊ីថា និង អ្នកស្រី នូ សម្បត្តិ ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ២៣៩ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៨ - របស់សាលាឧទ្ធរណ៍លើសេចក្ដីសំរេចទាំងមូល ។

- តាមពាក្យបណ្ដឹងចុះថ្ងៃទី ១៦ . ១១. ១៩៩៧ របស់ឈ្មោះ ស៊ុយ ហៀង ប្ដឹងពីឈ្មោះ ហៀង ស៊ីថា ឃុបឃិតគំនិតជាមួយម្ដាយឈ្មោះ នូ សម្បត្តិ សរសេរកិច្ចសន្យាជំពាក់លុយខ្លួនចំនួន ៤៥០០ដុល្លារអាមេរិក ដោយក្លែងបន្លំមេដៃ ឈ្មោះហៀង ម៉ាលីវត្តី និង ហៀង ម៉ាលីដា ជាអ្នកធានាបំណុល ។

- បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តពោធិ៍សាត់ ថា :

គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ហៀង ស៊ីថា ភេទ ប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិពាលញែក ១ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ពីបទ ក្លែងបន្លំនិមិត្តសញ្ញា - "ស្នាមមេដៃ" ប្រព្រឹត្តនៅភូមិពាលញែក ១ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ កាលពី ថ្ងៃទី ខែសីហា ឆ្នាំ ១៩៩៥ ។

- បានឃើញ ដីកាលើកលែងចោទ លេខ ២១អ.ក.៩៨ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការខេត្តពោធិ៍សាត់ ដែលបានសំរេច :

១ - លើកលែងចោទលើឈ្មោះ ហៀង ស៊ីថា ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិពាលញែក ១ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ពីបទ : ក្លែងបន្លំនិមិត្តសញ្ញា - "ស្នាមមេដៃ" ដែលមានចែងក្នុងមាត្រា ៤៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០.កញ្ញា១៩៩២

២ - តម្កល់រឿងទុកមិនចាត់ការ លើសំណុំរឿងព្រហ្មទណ្ឌលេខ ១២៥ ចុះថ្ងៃទី ០៤.១២.៨៧ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៣ ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ១៩៨៨ របស់ឈ្មោះស៊ុយ ហៀង ដែលប្តឹងតវ៉ាដីកាសំរេចលើកលែងចោទលេខ ២១អ.ក.៨៨ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៨៨ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តពោធិ៍សាត់ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា ៖

បដិសេធដីកាលើកលែងចោទលេខ ២១អ.ក.៨៨ ចុះថ្ងៃទី ១៦.០២.៨៨ របស់ព្រះរាជអាជ្ញាអម តុលាការខេត្តពោធិ៍សាត់ ចោលជាអសារបង់ និង បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ១២៥ ចុះថ្ងៃទី០៤.១២.៨៧ ទៅតុលាការខេត្តពោធិ៍សាត់ដើម្បីចាត់ការតាមនីតិវិធីច្បាប់ឡើងវិញ ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២៣៩ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៨៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច ៖

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៧.០២.១៩៨៨ របស់ឈ្មោះស៊ុយ ហៀង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - បដិសេធដីកាលើកលែងចោទលេខ ២១អ.ក.៨៨ ចុះថ្ងៃទី១៦.០២.៨៨ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តពោធិ៍សាត់ ចោលជាអសារបង់ ។

៣ - ចោទប្រកាន់ឈ្មោះ នូ សម្បត្តិ ភេទស្រី អាយុ ៦៥ឆ្នាំ និង ឈ្មោះហៀង ស៊ីថា ភេទប្រុស អាយុ ៣៤ឆ្នាំ ពីបទ ក្លែងស្នាមមេដៃ ប្រព្រឹត្តនៅភូមិពាលញែក ០២ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ កាលពីខែ០៨.៨៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥០ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០.០៩.៨២ ។

៤ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌ លេខ ១២៥ ចុះថ្ងៃទី ០៤.១២.៨៧ របស់សាលាឧទ្ធរណ៍ និងជនល្មើសទៅចៅក្រមស៊ើបអង្កេតតុលាការខេត្តពោធិ៍សាត់ ដើម្បីចាត់ការតាមនីតិវិធី ។

៥ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ ហៀង ស៊ីថា និង នូ សម្បត្តិ ។

បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៨៩ របស់ជនជាប់ចោទឈ្មោះ នូ សម្បត្តិ និង ឈ្មោះ ហៀង ស៊ីថា ដែលបានប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២៣៩ ចុះថ្ងៃទី ១៨.១១.៨៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណា ចុះថ្ងៃទី២៧.០៤.១៩៨៩ របស់ឈ្មោះ នូ សម្បត្តិ និង ឈ្មោះហៀង ស៊ីថា "ជាម្ចាស់បណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណាតប ចុះថ្ងៃទី ១៣.០២.១៩៨៩ របស់ឈ្មោះ ស៊ុយ ហៀង "ជាចុងបណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់សំណាកសាវំតាជាតិ របស់ជនជាប់ចោទឈ្មោះ នូ សម្បត្តិ "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា :

១- ឃើញថា ហេង ស៊ីថា មិនបានក្លែងស្នាមមេដៃទេ ព្រោះខ្លួនគ្រាន់តែសរសេរកិច្ចសន្យា អោយម្តាយឈ្មោះនូ សម្បត្តិ និង ម្ចាស់បំណុលឈ្មោះ ស៊ុយ ហេង ។

២- ចម្លើយជនល្មើសឈ្មោះនូ សម្បត្តិ ថា : ខ្លួនបានយកកិច្ចសន្យានេះទៅអោយចៅដីដូនមួយផ្តិតមេដៃជំនួសក្នុងកិច្ចសន្យា ក្រោយពីផ្តិតរួច ខ្លួនថា បានយកកិច្ចសន្យានេះទៅអោយ ស៊ុយ ហេងនៅនឹងផ្ទះ ខ្លួនឯង ។

ដូច្នេះ មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ នូ សម្បត្តិ តែមិនមានបទល្មើសដាក់បន្ទុកលើឈ្មោះហេង ស៊ីថាទេ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ចុះ ។

- បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ ហេង ស៊ីថា "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ សំរេចមិនយុត្តិធម៌មកលើរូបខ្ញុំបាទ ដោយខ្ញុំបាទពុំមានកំហុសល្មើសនឹងច្បាប់ឡើយ ព្រោះខ្ញុំគ្រាន់តែជាអ្នកសរសេរកិច្ចសន្យាអោយភាគីទាំងសងខាង រវាងម្តាយខ្ញុំឈ្មោះនូ សម្បត្តិ និង អ្នកស្រីស៊ុយ ហេង ហើយខ្ញុំបាទក៏ជិះម៉ូតូចេញធ្វើការ ដូច្នេះខ្ញុំមិនបានផ្តិតមេដៃលើកិច្ចសន្យានោះទេ ខ្ញុំបាទសូមបដិសេធសាលដីកាព្រហ្មទណ្ឌលេខ២៣៨ ចុះថ្ងៃទី២៨.១១.៩៨ របស់សាលាឧទ្ធរណ៍ ។

- បានស្តាប់សារណា របស់ជនជាប់ចោទឈ្មោះនូ សម្បត្តិ "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះ ។

- បានស្តាប់ចម្លើយដោះសារ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ទ្រាយ យ៉េង ជាប្តីរបស់អ្នកស្រីស៊ុយ ហេង "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : ក្នុងកិច្ចសន្យានោះ ឈ្មោះហេង ស៊ីថា ជាអ្នកសរសេរ ហើយយកក្រដាសកិច្ចសន្យានោះជិះម៉ូតូចេញទៅក្រៅមួយសន្ទុះ ពេលត្រឡប់មកវិញ ដោយក្រដាសកិច្ចសន្យានោះមានស្នាមមេដៃ សូមបញ្ជាក់ថា ពេលហេង ស៊ីថាកាន់ក្រដាសកិច្ចសន្យានោះចេញ មិនទាន់ផ្តិតមេដៃទេ លុះត្រឡប់មកវិញ កិច្ចសន្យានោះបែរជាមានស្នាមមេដៃជាស្រេច ដូច្នេះ ស្នាម លើកិច្ចសន្យានោះពិតជាស្នាមមេដៃរបស់ឈ្មោះ ហេង ស៊ីថា សូមលោកតុលាការជួយរកយុត្តិធម៌អោយខ្ញុំបាទផង ព្រោះក្នុងរឿងនេះខ្ញុំបាទខានសាក្សីដឹងឮ ។

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់លោក ពុធ ធារី ជាមេធាវីការពារអោយជនជាប់ចោទឈ្មោះ ហេង ស៊ីថា "ម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា :

កូនក្តីខ្ញុំឈ្មោះ ហេង ស៊ីថា គ្រាន់តែម្តាយឈ្មោះនូ សម្បត្តិអោយសរសេរក្នុងកិច្ចព្រមព្រៀងជាមួយម្ចាស់បំណុលឈ្មោះ ស៊ុយ ហេង គឺមានន័យថាអ្នកសរសេរ មិនមែនជាអ្នកផ្តិតមេដៃទេ ដូច្នេះ សក្សានុម័តគឺផ្លាត់លើម្តាយឈ្មោះនូ សម្បត្តិ ដែលជាអ្នកខ្ចីប្រាក់ពីអ្នកស្រី ស៊ុយ ហេង រឿងនេះគ្មានទាក់ទងនឹងកូនក្តីខ្ញុំទេ ព្រោះកូនក្តីខ្ញុំសរសេរកិច្ចសន្យានោះ គឺតាមការព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុលតែប៉ុណ្ណោះ ហើយម្យ៉ាងទៀតនៅតុលាការខេត្ត ក៏មិនបានធ្វើការចោទប្រកាន់មកលើកូនក្តីខ្ញុំឈ្មោះហេង ស៊ីថានេះដែរ ព្រោះថាក្នុងពេលសរសេរកិច្ចសន្យានោះមានសាក្សីគ្រាន់តែឃើញឈ្មោះហេង ស៊ី-ថា ជាអ្នកសរសេរ និង ឃើញជិះម៉ូតូទៅក្រៅតែប៉ុណ្ណោះ ដូច្នេះ ឃើញថា : គ្មាន -

បន្ទុកណាមួយ ដែលចោទថាឈ្មោះ ហៀង ស៊ីថា ផ្តិតមេដៃលើកិច្ចសន្យានោះឡើយ ខ្ញុំសូមបដិសេធសាលដីកាព្រហ្មទណ្ឌ របស់សាលាឧទ្ធរណ៍ ។

- បានស្តាប់ចម្លើយដោះសារបន្ថែម របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឡាយ ឈួន "ចុងបណ្តឹងសាទុក្ខ" នាពេលសវនាការ ថាៈ ខ្ញុំនៅតែចោទប្រកាន់លើឈ្មោះ ហៀង ស៊ីថា ជាអ្នកផ្តិតមេដៃលើកិច្ចសន្យានោះជានិច្ច ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការអមតុលាការកំពូល ថាៈ

ពុំមានអ្នកណាម្នាក់ ដែលឃើញហៀង ស៊ីថា ផ្តិតស្នាមមេដៃកិច្ចសន្យានោះទេ ហើយឈ្មោះហៀង-ស៊ីថា ដែលគ្រាន់តែសរសេរកិច្ចសន្យា មិនមែនជាភាគីនៃកិច្ចសន្យា ដូច្នេះសូមតម្កល់សេចក្តីសន្និដ្ឋាននៅ-ដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណា របស់ឈ្មោះនូ សម្បត្តិ ចម្លើយដោះសាររបស់ជនជាប់ចោទហៀង-ស៊ីថា ដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានរបស់មេធាវីនៃជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះនូ សម្បត្តិ និង ហៀង ស៊ីថា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង- និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចចោទប្រកាន់ឈ្មោះនូ សម្បត្តិ ពីបទក្លែងស្នាមមេដៃ តាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល នោះជាការត្រឹមត្រូវហើយ ប៉ុន្តែការចោទប្រកាន់ទៅលើឈ្មោះហៀង ស៊ីថា ដែលគ្រាន់តែសរសេរកិច្ចសន្យា ហើយមិនមែនភាគីនៃកិច្ចសន្យា ដែលក្លែងស្នាមមេ-ដៃ នោះជាការភាន់ច្រឡំ ពីព្រោះថា ការសរសេរដោយពុំទាន់មានស្នាមមេដៃ ពុំទាន់បង្កព្យសនកម្មនៅឡើយទេ ។

- យល់ឃើញថា ឈ្មោះ នូ សម្បត្តិបានធ្វើសារណាការពារផលប្រយោជន៍របស់ខ្លួនហើយ ប៉ុន្តែពុំបានចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២៣៩ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលា-ឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ លើកលែងតែការចោទប្រកាន់លើឈ្មោះ ហៀង ស៊ីថា ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដី ចំពោះមុខជនជាប់ចោទឈ្មោះ ហៀង ស៊ីថា និង ដើមបណ្ដឹង - រដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះនូ សម្បត្តិ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្ដឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះនូ សម្បត្តិទុកជា ត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែលើកចោលដោយខុសនឹងគតិច្បាប់ ។

- ទទួលបណ្ដឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះហៀងស៊ីថា ទុកជា ត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៣៩ ចុះថ្ងៃទី ១៥ខែវិច្ឆិកា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចទី ៣ ដែលត្រូវកែប្រែទៅជា :

ក - ចោទប្រកាន់ឈ្មោះនូ សម្បត្តិ ភេទ ប្រុស អាយុ២៥ឆ្នាំ ពីបទក្លែងត្រាមេដៃ ប្រព្រឹត្តនៅភូមិ ពាលញែក ២ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ កាលពីខែ១០ ឆ្នាំ១៩៩៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា ៤០ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០.០៩.១៩៩២

ខ - តម្កល់មិនចាត់ការ ពីបទក្លែងត្រាមេដៃលើឈ្មោះហៀង ស៊ីថា ។

៣ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ១៨ ចុះថ្ងៃទី ៣១ ខែមិនា ឆ្នាំ១៩៩៩ របស់តុលាការកំពូលទៅ - តុលាការខេត្តពោធិ៍សាត់ ដើម្បីចាត់ការតាមច្បាប់ ។

៤ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃ ១៥ ខែមិថុនា ឆ្នាំ២០០០ ។